# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៅគខនយ
# ថ្ងៃទី១៣ មេសា ២០១៧

អត្ថបទទី១៖ សរ ១២,១-៨.១១-១៤
អត្ថបទទី២៖ ១ករ ១១,២៣-២៦
ដំណឹងល្អ៖ យហ ១៣,១-១៥

បងប្អូនជាទីស្រឡាញ់!

អាទិត្យនេះជាបុណ្យដែលយើងត្រូវនៅស្ងៀមស្ងាត់ ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូដែលកំពុងបូជាជីវិត។ ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូ ដែលកំពុងជប់លៀងចុងក្រោយជាមួយក្រុមសាវ័ក យើងនឹកឃើញដល់ព្រះយេស៊ូដែលអង្គុយរួមតុ នឹកឃើញដល់ក្រុមគ្រីស្តទូត និងមាននាងម៉ារីនិងស្ត្រីខ្លះទៀតកំពុងអង្គុយរួមតុជាមួយព្រះយេស៊ូ។ គេជួបជុំគ្នា ដោយសារព្រះយេស៊ូអញ្ជើញគេឲ្យប្រារព្ធបុណ្យចម្លង ប៉ុន្តែព្រះយេស៊ូមានសម្តីប្លែកជាពិសេសនៅពេលចែកនំប៉័ងនិងស្រា ដែលគេធ្លាប់បរិភោគជារៀងរាល់ឆ្នាំក្នុងបុណ្យចម្លង។ ព្រះយេស៊ូបានយកនំប៉័ងហើយមានព្រះបន្ទូលថា៖ **"នេះជាព្រះកាយរបស់ខ្ញុំដែលបានបូជាជីវិតសម្រាប់អ្នករាល់គ្នា"** សាវ័កទាំងអស់គេភ្ញាក់ និងឆ្ងល់អំពីពាក្យដែលព្រះយេស៊ូមានព្រះបន្ទូល។ ព្រះយេស៊ូបានណែនាំឲ្យយើងយកនំប៉័ង ដែលនំប៉័ងនេះជារូបកាយរបស់ព្រះគ្រីស្តផ្ទាល់។ ព្រះយេស៊ូបានលើកពែងស្រាទំពាំងបាយជូរ ហើយមានព្រះបន្ទូលថា៖ **"នេះជាលោហិតរបស់ខ្ញុំដែលបង្ហូរដើម្បីរំដោះបាបរបស់អ្នករាល់គ្នា"** ណែនាំឲ្យក្រុមគ្រីស្តទូតឆ្ងល់ម្តងទៀត តើព្រះយេស៊ូកំពុងមានព្រះបន្ទូលអំពីអ្វី? ពេលនេះយើងយើងចូលក្នុងពិធីជប់លៀងចុងក្រោយរបស់ព្រះយេស៊ូ បន្តិចទៀតលោកបូជាចារ្យ នឹងយកនំប៉័ងនិងពែងស្រា ហើយមាននិយាយដូចព្រះយេស៊ូមានព្រះបន្ទូលពីដើម **"នេះជាព្រះកាយ នេះជាព្រះលោហិតដែលព្រះយេស៊ូបូជាសម្រាប់យើងយប់នេះ"**។ យប់នេះយើងនៅស្ងៀមស្ងាត់ ដើម្បីយើងឃើញព្រះយេស៊ូដែលអង្គុយជាមួយយើង និងព្រះយេស៊ូកំពុងជប់លៀងជាមួយយើង។ នៅពេលនោះក្រុមគ្រីស្តទូតមិនទាន់យល់អ្វីទាំងអស់ ព្រះយេស៊ូកំពុងនឹកដល់ថ្ងៃស្អែកដែលព្រះអង្គត្រូវបូជាជីវិតលើឈើឆ្កាង។ យើងដឹងថារូបកាយរបស់ព្រះគ្រីស្ត លោហិតរបស់ព្រះគ្រីស្តជាអ្វីដែលព្រះយេស៊ូបូជាពិតមែនលើឈើឆ្កាង។ ព្រះយេស៊ូមិនតែបូជាជីវិត ព្រះអង្គអញ្ជើញយើង ឲ្យយើងចូលនៅក្នុងការលះបង់ចោលរបស់ព្រះយេស៊ូដែរ។ ព្រះយេស៊ូចង់ឲ្យយើងធ្វើដំណើរជាមួយព្រះអង្គ យប់នេះព្រះយេស៊ូបានបង្ហាញសញ្ញាមួយយ៉ាងពិសេស គឺព្រះអង្គ

ចាប់ផ្តើមលាងជើងដល់ក្រុមគ្រីស្តទូត។ ព្រះយេស៊ូដែលជាព្រះជាម្ចាស់ ព្រះយេស៊ូដែលបានប្រទានជីវិត ដែលបានណែនាំឲ្យយើងស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ព្រះយេស៊ូលុតជង្គង់នៅមុខខ្ញុំដើម្បីលាងជើងខ្ញុំដែរ។

យប់នេះជាពេលវេលាមួយ ដើម្បីចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូយ៉ាងច្បាស់លាស់ បីឆ្នាំដែលព្រះយេស៊ូបានប្រកាសដំណឹងល្អ ដោយណែនាំឲ្យមនុស្សបាបកែប្រែចិត្តគំនិត និងទទួលជីវិតថ្មី បានព្យាបាលអ្នកជំងឺ ជនពិការ បានជាសាស្បើយ ព្រះអង្គបានប្រកាស់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់សម្រាប់អ្នកក្រីក្រ។ មហាជនសប្បាយចិត្តស្តាប់ព្រះយេស៊ូ គេទទួលជីវិតថ្មីពីព្រះអង្គដោយមានអំណរសប្បាយយ៉ាងពិតប្រាកដ។ យប់នេះយើងយល់អំពីអត្ថន័យនៃការលះបង់របស់ព្រះយេស៊ូ គឺដើម្បីបង្ហាញសេចក្តីស្រឡាញ់មនុស្សទាំងអស់។ នៅពេលព្រះយេស៊ូទៅដល់ថ្ងៃកំណត់នៃជីវិតរបស់ព្រះអង្គលើផែនដីនេះ ព្រះអង្គនៅតែបង្ហាញសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះយើងម្នាក់ៗ។ ព្រះយេស៊ូបានយកនំប៉័ង និងពែងស្រា ដើម្បីធ្វើជារូបកាយនិងលោហិតឲយើងមានជីវិត ឲ្យយើងទទួលសេចក្តីស្រឡាញ់របស់ព្រះយេស៊ូនៅក្នុងជីវិតយើងថែមទៀត។ ព្រះយេស៊ូបានប្រទានជីវិតផ្ទាល់របស់ព្រះអង្គសម្រាប់យើងទាំងអស់គ្នា យប់នេះយើងចូលនៅក្នុងការអស្ចារ្យដែលព្រះយេស៊ូប្រទានជីវិតឲ្យមនុស្សលោក។ បងប្អូនដែលទទួលព្រះកាយនិងព្រះលោហិតយប់នេះជាឱកាសមួយដើម្បីធ្វើជាផ្លូងតែមួយជាមួយព្រះយេស៊ូ និងដើម្បីយល់ថាជីវិតខ្ញុំត្រូវតែស្រឡាញ់ដូចព្រះយេស៊ូស្រឡាញ់ដែរ ជីវិតខ្ញុំត្រូវតែណែនាំឲ្យអ្នកក្រីក្រ អ្នកជំងឺ អ្នកតូចតាចមានសេចក្តីសង្ឃឹម។ នៅពេលព្រះយេស៊ូលាងជើង ព្រះអង្គមានព្រះបន្ទូលថា **"ចាប់ពីពេលនេះតទៅសូមលាងជើងឲ្យគ្នាទៅវិញទៅមក សូមស្រឡាញ់គ្នាដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា"**។ យប់នេះ ជាយប់ដែលបានកែប្រែពិភពលោកទាំងមូល នៅពេលព្រះយេស៊ូចូលក្នុងទុក្ខលំបាករបស់ព្រះអង្គ នៅពេលព្រះយេស៊ូណែនាំឲ្យយើងទៅជាអ្នកបម្រើ ព្រះយេស៊ូចង់ឲ្យយើងកសាងពិភពលោកថ្មីជាមួយព្រះអង្គ។ យើងដឹងថា អ្វីដែលព្រះយេស៊ូនិយាយ អ្វីដែលព្រះយេស៊ូប្រព្រឹត្ត គឺជាការពិតទាំងអស់។ យើងដឹងថាថ្ងៃនេះព្រះយេស៊ូសោយទិវង្គត ដើម្បីឲ្យយើងមានជីវិតថ្មី រូបកាយរបស់ព្រះយេស៊ូត្រូវតែស្លាប់លើឈើឆ្កាងឈាមរបស់ព្រះយេស៊ូត្រូវតែបង្ហូរនៅលើឈើឆ្កាងនៅថ្ងៃស្អែក។ ព្រះយេស៊ូអញ្ជើញយើងឲ្យយើងធ្វើដំណើរជាមួយព្រះអង្គ ដើម្បីបម្រើបងប្អូនឯទៀតៗឲ្យមានសេចក្តីសង្ឃឹម។ **តើយើងធ្វើដូចម្តេច**

**ដើម្បីបម្រើ? តើយើងធ្វើដូចម្តេច ដើម្បីណែនាំអស់អ្នកដែលអស់សង្ឃឹមមានសេចក្តីសង្ឃឹម? តើយើងធ្វើដូចម្តេច ដើម្បីធ្វើជាវត្តមានរបស់ព្រះយេស៊ូនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង? តើយើងធ្វើដូចម្តេច ដើម្បីសម្តែងធម៌មេត្តាករុណារបស់ព្រះអង្គដូចព្រះយេស៊ូបានសម្តែងអស់មួយជីវិតរបស់ព្រះអង្គ?** ពេលព្រះយេស៊ូបានលាងជើងឲ្យក្រុមសាវ័ក ពេលនោះលោកយ៉ូដាស់ ចេញទៅហើយដោយមិនបានទទួលព្រះបន្ទូលដែលជាមរតករបស់ព្រះយេស៊ូ។ យប់នេះ យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ និងទទួលព្រះបន្ទូលមរតករបស់ព្រះយេស៊ូដែរ **"សូមស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"។** ព្រះយេស៊ូបានអញ្ជើញយើង ឲ្យយើងទៅសួមច្បារកេតសេម៉ានី ដើម្បីអធិដ្ឋានជាមួយព្រះអង្គ ប៉ុន្តែក្រុមសាវ័កនៅតែមិនយល់អំពីអ្វីដែលកំពុងកើតឡើង។ ព្រះយេស៊ូដែលត្រូវលះបងចោលជីវិត នេះជារូបកាយ នេះជាលោហិតដែលត្រូវប្រទានសម្រាប់អ្នករាល់គ្នា។

យើងអរព្រះគុណព្រះជាម្ចាស់ ដែលបានចាត់ព្រះបុត្រាជាទីស្រឡាញ់របស់ព្រះអង្គ ដើម្បីឲ្យយើងមានជីវិត។ ពីថ្ងៃដែលព្រះយេស៊ូចាប់កំណើតជាមនុស្សក្នុងភូមិបេថ្លេហឹមរហូតដល់យប់នេះ ដែលព្រះយេស៊ូបានលះបង់និងប្រទានរូបកាយនិងព្រះលោហិត ដោយសោទិវង្គតលើឈើឆ្កាង និងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដែលណែនាំឲ្យយើងធ្វើជាតែមួយជាមួយព្រះយេស៊ូ ដោយទទួលអំណរសប្បាយនៃដំណឹងល្អ។ អំណរសប្បាយដែលណែនាំឲ្យយើងទៅជាមនុស្សថ្មីដែរ ធ្វើជាអ្នកបម្រើផង ជាអ្នកចេះស្រឡាញ់ផង ជាគ្រីស្តទូតដែលទៅប្រកាសដំណឹងល្អ ដើម្បីឲ្យមនុស្សជាច្រើនទទួលជីវិតថ្មី និងរកឃើញពន្លឺនៅក្នុងជីវិត។ យើងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍ដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។ យើងអធិដ្ឋាន សម្រាប់យុវជនយុវនារីដែលកំពុងគិតអំពីអនាគត់របស់ពួកគេ ដែលចង់បម្រើព្រះយេស៊ូ បម្រើព្រះសហគមន៍ បម្រើបងប្អូនឯទៀតៗ អស់ពីជំនឿ អស់ពីសេចក្តីស្រឡាញ់ អស់ពីកម្លាំងកាយចិត្ត។ យើងបើកដួងចិត្តរបស់យើង ដើម្បីចូលនៅក្នុងអធិដ្ឋានរបស់ព្រះគ្រីស្តនៅសួនច្បារកេតសេម៉ានី **មិនមែនតាមចិត្តទូលបង្គំ ប៉ុន្តែទូលបង្គំធ្វើតាមព្រះហឫទ័យរបស់ព្រះបិតា** ឲ្យយើងរួមគ្នានិយាយតាមព្រះយេស៊ូពិតមែន យើងមិនធ្វើតាមចិត្តយើង យើងធ្វើតាមព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា ដើម្បីឲ្យមនុស្សលោករកឃើញពន្លឺ រកឃើញសេចក្តីសង្ឃឹម និងមានបទពិសោធន៍អំពីមេត្តាករុណាពិតប្រាកដមែន។ អាម៉ែន។